ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខាធិការដ្ឋានរដ្ឋបាលសរុប

# កំណត់ហេតុ
## កិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២
## ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា

ថ្ងៃអង្គារ បីកើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.សពីរពាន់ប្រាំរយហុកសិបពីរ ត្រូវនឹងថ្ងៃទីដប់បួន ខែសីហា ឆ្នាំពីរពាន់ដប់ប្រាំបី វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានបើកកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមនៅកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជបជ ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោក លោកស្រីតំណាងអង្គការការីតាស់កម្ពុជា តំណាងសាសនាទាំង៤ នៅកម្ពុជា និងមន្ត្រីពាក់ព័ន្ធមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើម លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គជបជ លោក លោកស្រីតំណាងអង្គការការីតាស់កម្ពុជា តំណាងសាសនាទាំង៤ និងមន្ត្រីពាក់ព័ន្ធទាំងអស់នាពេលនេះ។

លោកជំទាវប្រធានអង្គប្រជុំ បានបញ្ជាក់អំពីការរៀបចំវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃព្រហស្បតិ៍ ៤រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាលើកទី២ហើយដែលយើងទាំងអស់គ្នាបានរួមគ្នាប្រារព្ធពិធីអន្តរសាសនានេះឡើង។ ដូច្នេះយោងលើបទពិសោធន៍ដែលយើងមានកន្លងមក គឺត្រូវធ្វើយ៉ាងណារៀបចំឲ្យបានល្អប្រសើរជាងឆ្នាំមុន។ លោកជំទាវ បានស្នើឲ្យសមាជិកអង្គប្រជុំជួយធ្វើការកែតម្រូវខ្លឹមសារ នៃសារួមក្នុងពិធីសូត្រមន្ត អធិដ្ឋាន ក៏ដូចជាដំណើរការកម្មវិធី នៃវេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២ ដើម្បីឲ្យសមស្របទៅនឹងពេលវេលា។

បន្ទាប់ពីធ្វើការកែតម្រូវលើខ្លឹមសារ និងដំណើរការ វេទិកាអន្តរសាសនាថ្នាក់ជាតិលើកទី២រួចមក លោកជំទាវប្រធាន និងសមាជិកអង្គប្រជុំបានសម្រេចកាត់បន្ថយ សាររួមក្នុងពិធីសូត្រមន្ត អធិដ្ឋាន ពី១៣ចំណុច មកត្រឹម៩ចំណុច ដែលមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

១.អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ ជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ត្រូវជៀសវាង

២.យើងទាំងអស់គ្នា ប្រឆាំងដាច់ខាត នូវបទឧក្រិដ្ឋជួញដូរមនុស្ស និងឧក្រិដ្ឋកម្មដទៃទៀត

៣.សូមគាំទ្រគោលនយោបាយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ ជីវភាពកម្មករ កសិករ មន្ត្រីរាជការ ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន

៤.យើងទាំងអស់គ្នា គ្រប់ភេទ គ្រប់វ័យ មិនមែនជាទំនិញសម្រាប់ឲ្យជនល្មើសជួញដូរ ឬកេងប្រវ័ញ្ចឡើយ

៥.យើងខ្ញុំគាំទ្រ និងជំរុញ ការផ្តន្ទាទោសជនល្មើស ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ

៦.ប្តេជ្ញាពង្រីកការយល់ដឹង អំពីផលប៉ះពាល់ នៃអំពើជួញដូរមនុស្ស ទៅសហគមន៍យើង ដើម្បីបានរួចផុតពីភាពរងគ្រោះ

៧.ជួយថែទាំ ឧបត្ថម្ភ គាំទ្រ និងមិនរើសអើង ជាពិសេសស្ត្រី និងកុមារ

៨.ការជួយឧបត្ថម្ភ គាំទ្រដល់ជនរងគ្រោះ គឺជាអំពើល្អ និងទទួលបានបុណ្យកុសល

៩.មនុស្សទាំងឡាយ ទោះមានជំនឿ សាសនា និងស្ថានភាពខុសគ្នាយ៉ាងណា ក៏នៅតែជាបងប្អូនយើង ដែលត្រូវផ្តល់ការយកចិត្តទុកដាក់ និងអាណិតស្រឡាញ់ដូចៗគ្នា។

យើងសូមគាំទ្រយ៉ាងម៉ឺងម៉ាត់ !

យើងសូមប្តេជ្ញាអនុវត្ត !

យើងទាំងអស់គ្នា រួមគ្នា ប្រឆាំងដាច់ខាត អំពើជួញដូរមនុស្ស!!!!

នៅទីបញ្ចប់ នៃកិច្ចប្រជុំ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជបជ បានស្នើឲ្យសមាជិកអង្គប្រជុំទាំងអស់អញ្ជើញមកជួបប្រជុំបន្ត នាថ្ងៃសុក្រ ទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ០៩ព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គជបជ ដើម្បីធ្វើការកែសម្រួល និងសម្រេចលើកម្មវិធីអន្តរសាសនាថ្នាក់ជាតិលើកទី២។

កិច្ចប្រជុំពិភាក្សា បានបញ្ចប់នៅវេលាម៉ោង ដប់ពីរ ថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល។

ថ្ងៃអង្គារ ៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨

**អ្នកធ្វើកំណត់ហេតុ**

**គោរពជូន**

**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃអង្គារ ៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨

**ឧត្តមសេនីយ៍ឯក. គង់-ពុទ្ធី**

15/08/18